# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## តំណាង សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុង
## ពិធីបិទសន្និបាតបូកសរុបសមិទ្ធផលការងាររយៈពេល ៥ ឆ្នាំ (២០១៨-២០២២) និង លើកទិសដៅការងារឆ្នាំ ២០២៣ របស់ក្រសួងមុខងារសាធារណៈ

*សាលាភូមិន្ទរដ្ឋបាល, ថ្ងៃពុធ ទី ២២ ខែ មីនា ឆ្នាំ ២០២៣*

- *ឯកឧត្តម **ពេជ្រ ប៊ុនធិន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស;*
- *ឯកឧត្តម **ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ;*
- *ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន;*
- *លោកជំទាវកិត្តិបណ្ឌិត **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី;*
- *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក, សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្ដីសោមនស្ស និង កិត្តិយសក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុត ពី **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ**ព្រះរាជាណាចក្រកម្ពុជា** ចូលរួមជាអធិបតីក្នុង **ពិធីបិទសន្និបាតបូកសរុបសមិទ្ធផលការងាររយៈពេល ៥ ឆ្នាំ (២០១៨-២០២២) និង លើកទិសដៅការងារឆ្នាំ ២០២៣ របស់ក្រសួង**

**មុខងារសាធារណៈ** ។ ក្នុងឱកាសដ៏វិសេសវិសាលនេះ, ខ្ញុំសូមពាំនាំមកនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជូនចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងមុខងារសាធារណៈ ព្រមទាំងថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃបណ្ដាក្រសួង-ស្ថាប័នថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានឆ្លៀតពេលដ៏មានតម្លៃចូលរួមក្នុងសន្និបាតនេះ ។

ខ្ញុំសូមអរគុណ **ឯកឧត្តម ហ៊ុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** ដែលបានដឹកនាំរៀបចំ និង សម្របសម្រួលកិច្ច-ដំណើរការនៃអង្គសន្និបាត ព្រមទាំងបានធ្វើរបាយការណ៍យ៉ាងក្បោះក្បាយ អំពីលទ្ធផលរបស់អង្គសន្និបាត និង សមិទ្ធផលការងារដ៏ល្អ ដែលសម្រេចបាននាពេលកន្លងមក នៅក្នុងវិស័យមុខងារសាធារណៈ, ជាពិសេស ក្នុងបរិបទដ៏លំបាកនៃវិបត្តិជំងឺកូវីដ-១៩ និង ភាពមិនប្រាកដ-ប្រជាខ្ពស់ នៃការប្រែប្រួលជាសកល ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសម្ដែងនូវការកោត-សរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី** ព្រមទាំង ឯកឧត្តម, លោកជំទាវ ជារដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ, អគ្គនាយក, អគ្គាធិការ ព្រមទាំងថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងមុខងារសាធារណៈ ដែលបានប្ដេជ្ញាចិត្តខ្ពស់ និង ខិតខំយកចិត្តទុកដាក់ លើការដឹកនាំ, គ្រប់គ្រង និង អភិវឌ្ឍវិស័យមុខងារសាធារណៈ ក៏ដូចជាការងារកែទម្រង់រដ្ឋបាលសាធារណៈ យ៉ាងសកម្ម ប្រកបដោយប្រសិទ្ធភាពខ្ពស់, ជាពិសេសការធ្វើទំនើបនីយកម្ម, ប្រកបដោយនវានុវត្តន៍ ដោយផ្អែកលើធនធានមន្ត្រីដែលមានស្រាប់, រៀបចំកសាង និង អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និង គ្រប់គ្រងបៀវត្ស (HRMIS); ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណមន្ត្រីរាជការស៊ីវិល ដោយប្រើ Smart Card; និង ប្រព័ន្ធ MCS Mobile App ដើម្បីចូលរួមចំណែកក្នុងការកសាងរដ្ឋាភិបាលឌីជីថល ។

– ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ក្នុងរយៈពេលប្រមាណ ៣ ឆ្នាំកន្លងទៅនេះ, ទោះបីជាជំងឺកូវីដ-១៩ បានឆ្លងរាលដាលនៅគ្រប់បណ្ដាប្រទេសនៅលើពិភពលោក និង បង្កឱ្យមានភាពមិនប្រាកដប្រជាខ្ពស់ តាមរយៈ

ការបំប្លែងខ្លួនជាប្រភេទវីរុសថ្មីជាបន្តបន្ទាប់ក្តី, ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិត, ភាពឈ្លាសវៃ, និង ភាពបុរេសកម្ម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, កម្ពុជាបានក្លាយជាប្រទេសឈានមុខមួយ, ទាំងក្នុងកម្រិតតំបន់ និង សកលលោក, ដែលបានគ្រប់គ្រងសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ យ៉ាងល្អប្រសើរ, ពិសេស តាមរយៈការដាក់ចេញ និង ការអនុវត្ត ប្រកបដោយជោគជ័យ នូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឱ្យបាននូវភាពស៊ាំរឹងមាំ តាមអភិក្រមផ្ការីក ព្រមទាំងវិធានការរដ្ឋបាល, វិធានការសុខាភិបាល, វិធានការអប់រំ និង វិធានការច្បាប់ពាក់ព័ន្ធជាច្រើនផ្សេងទៀត ដែលមានភាពទន់ភ្លន់, ប៉ុន្តែម៉ឺងម៉ាត់ និង ច្បាស់លាស់ ។ ប្រការនេះ បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការទប់ស្កាត់ និង កាត់ផ្តាច់ខ្សែចម្លងជំងឺ និង កាត់បន្ថយផលប៉ះពាល់មកលើសុខភាព, សុខុមាលភាព និង អាយុជីវិតរបស់ប្រជាជនកម្ពុជាឱ្យនៅកម្រិតអប្បបរមា និង បានអនុញ្ញាតឱ្យកម្ពុជា អាចបើកប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ ចាប់តាំងពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២១ រហូតមកដល់បច្ចុប្បន្ន ប្រកបដោយភាពជឿជាក់, សុវត្ថិភាព និង ភាពធន់ ។

ជាមួយគ្នានេះ, ក្នុងគោលដៅទ្រទ្រង់, រក្សាលំនឹង និង ស្តារសកម្មភាពអាជីវកម្ម និង ធុរកិច្ច ឱ្យងើបឡើងវិញជាបណ្តើរៗ ព្រមទាំងជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា, រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការគោលនយោបាយ និង ក្របខណ្ឌយុទ្ធសាស្ត្រ ព្រមទាំងបានជំរុញអនុវត្តនូវកញ្ចប់វិធានការអន្តរាគមន៍ ជាបន្តបន្ទាប់ ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ ចំពោះជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ និង មន្ត្រី-បុគ្គលិកគ្រប់ប្រភេទផ្សេងទៀត ដែលបានទទួលរងនូវសម្ពាធ ពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។ ទោះស្ថិតក្នុងស្ថានការណ៍លំបាកយ៉ាងណាក៏ដោយ, ក៏មន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ និង មន្ត្រី-បុគ្គលិកគ្រប់ប្រភេទទាំងអស់ តែងតែទទួលបាននូវការបើកប្រាក់បៀវត្សជាទៀងទាត់ និង ទាន់ពេលនៅរៀងរាល់ ២ សប្តាហ៍ម្តង ព្រមទាំងទទួលបាននូវប្រាក់ឧបត្ថម្ភបន្ថែម ចំនួន ៥ ម៉ឺនរៀល នៅរៀងរាល់ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ និង បុណ្យភ្ជុំបិណ្ឌ ផងដែរ ។ លើសពីនេះ, ជាមួយនឹងការស្រាកស្រាន្តនូវការរីករាលដាលនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលក៏បានខិតខំ

ដំឡើងប្រាក់បៀវត្ស, ប្រាក់បំណាច់មុខងារ និង របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ, និវត្តជន និង មន្ត្រី-បុគ្គលិកគ្រប់ប្រភេទផ្សេងទៀត ព្រមទាំងបានបង្កើនប្រាក់សោធនប្រចាំខែ សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជនផងដែរ ទៅតាមលទ្ធភាពនៃថវិកាជាតិ ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២៣ នេះ, បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការទូទៅ ត្រូវបានដំឡើងដល់ ១ លាន ៣ សែនរៀល និង សម្រាប់គ្រូបង្រៀន ត្រូវបានដំឡើងដល់ ១ លាន ៤ សែនរៀល ខណៈដែលប្រាក់សោធនអប្បបរមាប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន, រួមបញ្ចូលទាំងអតីតយោធិន និង អតីតមន្ត្រីនគរបាលជាតិ, ត្រូវបានដំឡើងដល់ ៧៧ ម៉ឺនរៀល ។

– ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

វិធានការគោលនយោបាយ, វិធានការអន្តរាគមន៍ និង ក្របខណ្ឌយុទ្ធសាស្ត្រនានា ដែលត្រូវបានដាក់ចេញជាបន្តបន្ទាប់ មិនអាចសម្រេចជោគជ័យបានឡើយ ដរាបណាមិនមានការចូលរួមយ៉ាងសកម្ម ពីសំណាក់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលជាកម្លាំងចលករដ៏សំខាន់ក្នុងការទ្រទ្រង់ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ ក្នុងនោះ, ក្រសួងមុខងារសាធារណៈ និង គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលមានបេសកកម្ម និង ភារកិច្ចដឹកនាំ, គ្រប់គ្រង និង អភិវឌ្ឍវិស័យមុខងារសាធារណៈ ព្រមទាំងមន្ត្រីរាជការស៊ីវិល, បានបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់ និង សម្រេចបាននូវសមិទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ និង គួរជាទីមោទនៈ ។

ទោះជាយ៉ាងណាក្តី, នៅក្នុងបរិការណ៍ដែលពោរពេញទៅដោយបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជា នាបច្ចុប្បន្ន និង ទៅអនាគត, ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងការប្រែក្លាយបញ្ហាប្រឈមនានា ឱ្យទៅជាកាលានុវត្តភាព សម្រាប់ការកែទម្រង់ និង ការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា សំដៅបន្តធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងតំបន់ និង សកលលោក, ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួងមុខងារសាធារណៈ និង គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បន្តអនុវត្តការងារកែទម្រង់របស់ខ្លួន ក្នុងវិស័យមុខងារសាធារណៈ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

លើមូលដ្ឋាននេះ, ដើម្បីជាការចូលរួមក្នុងការកំណត់ទិសដៅការងារបន្តទៅមុខ ស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួង និង លទ្ធផលនៃអង្គសន្និបាត, ខ្ញុំក៏សូមផ្តល់នូវអនុសាសន៍មួយចំនួន ជូនក្រសួងមុខងារសាធារណៈ និង គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដូចខាងក្រោម៖

**ទី១.** រៀបចំធ្វើវិសោធនកម្ម ឬ តាក់តែងឡើងវិញ នូវច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ ១៩៩៤ ដើម្បីឱ្យមានសង្គតិភាពជាមួយលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និង ពង្រឹងការគ្រប់គ្រងវិស័យមុខងារសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព ។

**ទី២.** រៀបចំឱ្យបានរួចរាល់ នូវសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២៣-២០៣៥ ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលអនុម័ត ព្រមទាំងជំរុញការដាក់ឱ្យអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ជាដំណាក់កាលៗ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ទី៣.** ជំរុញការពិគ្រោះយោបល់ រៀបចំព្រះរាជក្រឹត្យ ស្តីពីការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវតម្លាភាព, គណនេយ្យភាព និង គុណាធិបតេយ្យ ។

**ទី៤.** លើកកម្ពស់សមត្ថភាពមន្ត្រីរាជការស៊ីវិល ឱ្យកាន់តែទូលំទូលាយ, ជាពិសេសសម្រាប់មន្ត្រីជាន់ខ្ពស់ និង មន្ត្រីមានតួនាទីដឹកនាំ និង គ្រប់គ្រងអង្គភាព នៅថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបន្តលើកកម្ពស់គុណភាព និង សមត្ថភាពបណ្តុះបណ្តាលរបស់សាលាភូមិន្ទរដ្ឋបាល, ការពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍នានា និង ការបង្កើនវគ្គបណ្តុះបណ្តាលខ្លី ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ក្រសួង-ស្ថាប័ន, ការសិក្សាស្រាវជ្រាវចងក្រងករណីសិក្សា និង ការរៀបចំវេទិកាផ្លាស់ប្តូរចំណេះដឹង, បទពិសោធន៍, ឧត្តមានុវត្តន៍ និង នវានុវត្តន៍ ក្នុងវិស័យសាធារណៈ ។

**ទី៥.** ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់មន្ត្រីសាធារណៈ, ជាពិសេស អធិការកិច្ចមុខងារសាធារណៈ ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រ និង គោលនយោបាយ ដែលរាជរដ្ឋាភិបាលបាន និង កំពុងរៀបចំ សម្រាប់នីតិកាលថ្មី ។

**ទី៦.** បង្កើនប្រសិទ្ធភាពលើការងារត្រួតពិនិត្យរដ្ឋបាល, បៀវត្ស និង ការគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ព្រមទាំងបន្តផ្តល់ការគាំទ្រដល់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស, ពិសេស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ទី៧.** បន្តចូលរួមកសាងរដ្ឋាភិបាលឌីជីថល តាមរយៈការលើកកម្ពស់សមត្ថភាពប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (HRMIS) ដើម្បីគាំទ្រការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស ក្នុងរដ្ឋបាលសាធារណៈ ឱ្យបានកាន់តែប្រសើរ ។

**ទី៨.** បន្តយកចិត្តទុកដាក់លើជីវភាពរស់នៅរបស់មន្ត្រីរាជការ តាមរយៈការកសាងបណ្តាញសុវត្ថិភាព ដើម្បីពង្រឹងការគាំពារសុខុមាលភាពមន្ត្រីរាជការ ។

**ទី៩.** ជំរុញការសិក្សា, ការវិភាគមុខងារ និង រចនាសម្ព័ន្ធ និង បន្ទុកបុគ្គលិក នៃស្ថាប័នសាធារណៈ ហើយលើមូលដ្ឋាននេះ រៀបចំដាក់ចេញនូវក្របខណ្ឌគោលនយោបាយ និង គោលការណ៍ណែនាំ សម្រាប់គ្រប់ក្រសួង-ស្ថាប័ន រៀបចំនូវចក្ខុវិស័យ និង ផែនការអភិវឌ្ឍស្ថាប័នរៀងៗខ្លួន ដើម្បីធានាប្រសិទ្ធភាព ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ស្របតាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន ។ និង

**ទី១០.** ជំរុញការរៀបចំ និង ការដាក់ឱ្យអនុវត្ត ជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ ក្នុងការវាយតម្លៃសមិទ្ធកម្មការងាររបស់មន្ត្រី និង ក្នុងការផ្តល់នូវការលើកទឹកចិត្ត ប្រកបដោយភាពសមស្រប និង សមធម៌ ។

– ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

មុននឹងបញ្ចប់, ខ្ញុំសូមគូសបញ្ជាក់ជូនឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ជ្រាបថា ភាពជោគជ័យនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ មិនចំណុះតែទៅលើការបោះជំហានទៅមុខលឿនតែម្នាក់ឯងរបស់ក្រសួងមុខងារសាធារណៈនោះទេ ពោលគឺគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ **«ត្រូវដើរដំណាលគ្នា និង ទៅមុខទាំងអស់គ្នា»** ។ ទស្សនាទាននេះមានន័យថា ក្រសួងមុខងារសាធារណៈ និង គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មិនមែនត្រឹមតែត្រូវតាក់តែង, រៀបចំ និង អនុវត្តកម្មវិធី ឬ គោលនយោបាយ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការកែទម្រង់រដ្ឋបាលសាធារណៈប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងត្រូវ

បង្កើនចំណេះដឹង, ចំណេះធ្វើ, ជំនាញ និង សមត្ថភាពដល់ភាគីពាក់ព័ន្ធទាំងអស់ ដែលជាតួអង្គដ៏សំខាន់ ក្នុងការអនុវត្តផ្ទាល់នៅតាមគ្រប់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ការយល់ដឹងអំពីសារៈប្រយោជន៍ និង បែបបទនីតិវិធីនៃការអនុវត្ត, ជាពិសេស ដើម្បីបង្កើនការចូលរួមអនុវត្ត ប្រកបដោយភាពបុរេសកម្ម, នវានុវត្តន៍ និង ការទទួលខុសត្រូវខ្ពស់ លើការងារកែទម្រង់រដ្ឋបាលសាធារណៈ ។

ទន្ទឹមនេះ, ដោយផ្អែកលើក្របខណ្ឌនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ក្រសួង-ស្ថាប័ន ត្រូវរៀបចំផែនការអនុវត្ត ដោយផ្សារភ្ជាប់ធនធាន និង សូចនាករសមិទ្ធកម្មក្នុងវង្វង់សមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ ។ រដ្ឋមន្ត្រីនៃក្រសួង និង ប្រធានស្ថាប័ននីមួយៗ ត្រូវពង្រឹងភាពជាម្ចាស់ ក្នុងការអនុវត្តផែនការ និង តាមដានវឌ្ឍនភាពការងារជាប្រចាំ ទៅតាមដំណាក់កាលសមស្របនីមួយៗ ។ ការកែទម្រង់ត្រូវផ្តើមចេញជាសំខាន់ពីការពង្រឹងភាពជាអ្នកដឹកនាំ និង ភាពជាម្ចាស់ ដោយត្រូវរៀបចំឧបករណ៍បច្ចេកទេស សម្រាប់គាំទ្រដល់ការអនុវត្ត និង ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង និង សមត្ថភាពមន្ត្រីរាជការនៅក្រោមឱវាទ ដើម្បីឈានទៅសម្រេចបាននូវលទ្ធផលតាមការគ្រោងទុក ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យ ជូនឯកឧត្តមរដ្ឋមន្ត្រី, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការស៊ីវិលគ្រប់លំដាប់ថ្នាក់របស់ក្រសួងមុខងារសាធារណៈ ក៏ដូចជាសមាជិក-សមាជិកាទាំងអស់នៃអង្គសន្និបាត ប្រកបដោយសុខភាពល្អបរិបូរណ៍, មានសុភមង្គលក្នុងក្រុមគ្រួសារ, សម្រេចជោគជ័យក្នុងគ្រប់ភារកិច្ច និង ជួបប្រទះតែពុទ្ធពរ និង ពរទាំង ៥ ប្រការ គឺ៖ **អាយុ, វណ្ណៈ, សុខៈ ពលៈ និង បដិភាណៈ** កុំបីឃ្លៀង-ឃ្លាតឡើយ ។

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-**ណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសបិទ **អង្គសន្និបាតបូកសរុបលទ្ធផលការងាររយៈពេល ៥ ឆ្នាំ (២០១៨-២០២២) និង លើកទិសដៅការងារសម្រាប់ឆ្នាំ ២០២៣ របស់ក្រសួងមុខងារសាធារណៈ** នាពេលនេះ ៕

***សូមអរគុណ!***